# ខាធី និង ឃ្វីនសី

ដោយ **អីវ៉ាន វ៉ាលិនថាញ និង ម៉ារីសា វីដឌីសុន**
ផ្អែកទៅលើដំណើររឿងពិត

*« មិត្រសំឡាញ់រមែងស្រឡាញ់គ្នានៅគ្រប់វេលា » ( សុភាសិត ១៧:១៧ ) ។*

ខាធីចូលចិត្តច្រៀង ។ នាងចូលចិត្តរាំ ។ ប៉ុន្តែនាងចូលចិត្តថ្ងៃអាទិត្យជាងអ្វីៗទាំងអស់ ! នោះគឺនៅពេលគាត់បានឃើញមិត្តរបស់គាត់ឈ្មោះឃ្វីនសី ។

ខាធីមានជំងឺរិបត្តក្រូម៉ូសូម ។ ជួនកាល នៅព្រះវិហារ គាត់ភាន់ច្រឡំ ហើយពុំដឹងថា ត្រូវធ្វើយ៉ាងណាទេ ។ ប៉ុន្តែគាត់បានដឹងថា ឃ្វីនសីនឹងនៅទីនោះដើម្បីជួយគាត់ ។

ឃ្វីនសីនឹងកាន់ដៃខាធី ហើយដើរជាមួយនាងទៅថ្នាក់អង្គការបឋមសិក្សា ។ ជួនកាលខាធីមានអារម្មណ៍ថាឡេះឡាស់អំឡុងម៉ោងពេលវេលាចែកចាយ ហើយឃ្វីនសីនឹងឱបនាង ។ វាបានជួយខាធី ឲ្យស្ងប់ស្ងៀមជានិច្ច ។ បន្ទាប់ពីពេលវេលាចែកចាយចប់ ឃ្វីនសីបានជួយខាធីរកថ្នាក់របស់នាង ។ ខាធីចូលចិត្តឃ្វីនសី ។

ថ្ងៃមួយ ខាធីបានដឹងថា មានរឿងមួយដ៏ក្រៀមក្រំបានកើតឡើងនៅក្នុងគ្រួសាររបស់ឃ្វីនសី ។ បងប្រុសរបស់ឃ្វីនសីឈ្មោះខូរីបានស្លាប់ ! ខាធីបានដឹងថា មិត្តរបស់នាងនឹងកើតទុក្ខ ។ នាងបានដឹងថា ឃ្វីនសីស្រឡាញ់បងប្រុសនាងខ្លាំងណាស់ ។

ម៉ាក់បានប្រាប់ខាធីថា យប់នេះមានមនុស្សនឹងទៅអគារសាសនាចក្រ ដើម្បីបង្ហាញដល់គ្រួសារឃ្វីនសីថា ពួកគេមានគេស្រឡាញ់ ។ បន្ទាប់មក នៅថ្ងៃស្អែកគឺជាបុណ្យសពរបស់ខូរី ។

ម៉ាក់បានសួរខាធីថា « តើកូនចង់ទៅព្រះវិហារជាមួយប៉ា និងម៉ាក់យប់នេះដែរឬទេ ? »

ខាធីបានងក់ក្បាល ។ នាងចង់ប្រាប់ឃ្វីនសីថា នាងស្រឡាញ់ឃ្វីនសី !

ម៉ាក់បានជួយខាធីស្លៀកពាក់សម្លៀកបំពាក់ស្អាតបាត ។ បន្ទាប់មក ពួកគេបានបើកឡានទៅព្រះវិហារ ។

ពេលពួកគេទៅដល់ទីនោះ ខាធីបានឃើញមនុស្សជាច្រើន ។ នាងបានដឹងថា ពួកគេមួយចំនួនមកពីព្រះវិហារ ។ នាងបានឃើញប៊ីស្សពរបស់នាង ។ នាងបានឃើញគ្រូបង្រៀនថ្នាក់អង្គការបឋមសិក្សារបស់នាង ។ ប៉ុន្តែនាងពុំបានឃើញមិត្តរបស់នាងទេ ។



ខេធីបានសួរ « ម៉ាក់ តើឃ្វីនសីនៅឯណា ? »

ម៉ាក់ពុំដឹងទេ ។

ម៉ាក់បាននិយាយថា « ហេតុអ្វីយើងមិនសួរគេទៅ ? »

ជាទូទៅ ខាធីពុំចូលចិត្តនិយាយពេលមានមនុស្សច្រើននោះទេ ។ ប៉ុន្តែយប់នេះ នាងត្រូវតែរកឃ្វីនសី ។ ខាធីមានចិត្តក្លាហាន ។ នាងបានដើរសំដៅទៅរកប៊ីស្សព ។

នាងបានប្រាប់គាត់ថា « ឃ្វីនសីកើតទុក្ខ ខ្ញុំត្រូវរកឃ្វីនសី ! » ។

ប៊ីស្សពបានញញឹម ហើយបានចាប់ដៃខាធី ។ « អញ្ចឹង តោះទៅរកឃ្វីនសី » ។

រចនារូបភាពដោយ ខាធី ផេរី



ទាំងអស់គ្នា ទាំងប៊ីស្សព ម៉ាក់ និងខាធីបានដើរជុំវិញអគារ ។ ទីបំផុតពួកគេបានរកឃើញនាង ! ឃ្វីនសីកំពុងអង្គុយនៅកន្លែងកាច់ជ្រុងមួយ ។ គាត់មើលទៅដូចជាកើតទុក្ខក្រៀមក្រំណាស់ ។

ខាធីបានដើរទៅរកមិត្តនាង ហើយឱបនាង ។ គាត់បានគិតថា ឃ្វីនសីនឹកបងប្រុសនាងខ្លាំងណាស់ ។

ខាធីបាននិយាយថា « ឃ្វីនសីមិនជាអ្វីទេ ព្រះយេស៊ូវនឹងមើលថែខូរីហើយ » ។ នាងបានប៉ះសក់ឃ្វីនសីដោយប្រុងប្រយ័ត្ន ដើម្បីប្រាកដថា វាថ្នមៗ ។

ឃ្វីនសីបានចាប់ផ្ដើមយំ ។ ខាធីបានឱបនាងកាន់តែខ្លាំង ។

ខាធីបាននិយាយថា « ឃ្វីនសីមិនអីទេ ។ ព្រះយេស៊ូវនឹងមើលថែខូរីហើយ » ។

ឃ្វីនសីបានយំហើយយំទៀត ។ ខាធីបានបន្តឱបមិត្តរបស់នាង ។ មួយរយៈក្រោយមក ឃ្វីនសីបានស្ងាត់បន្តិច ។ នាងនៅតែរដឹតរដកនៅឡើយ ប៉ុន្តែនាងពុំយំខ្លាំងដូចមុនទេ ។ នាងបានងើយមើលទៅខាធី ។

នាងបាននិយាយថា « អរគុណខាធី ។ ឯងនិយាយត្រូវហើយ ។ ព្រះយេស៊ូវនឹងមើលថែបងប្រុសរបស់ខ្ញុំហើយ » ។

ខាធីបានរីករាយថា នាងអាចជួយមិត្តរបស់នាងឲ្យមានអារម្មណ៍ធូរស្បើយវិញ ។ នាងស្រឡាញ់ឃ្វីនសី ! ■

*អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា. ។*

**មិត្តដែលពិការ**

ពិការភាពមួយចំនួនធ្វើឲ្យរូបកាយមួយពិបាកធ្វើការ ។ ពិការភាពមួយចំនួនទៀតធ្វើឲ្យខួរក្បាលពិបាកធ្វើការ ។ មនុស្សមួយចំនួនមានពិការភាពដែលប៉ះពាល់ដល់ខួរក្បាល និងរូបកាយរបស់ពួកគេ ។ ទោះមានរឿងអ្វីក៏ដោយ *គ្រប់* ក្មេងទាំងអស់មានសារៈសំខាន់ និងជាបុត្រជាទីស្រឡាញ់របស់ព្រះ !

ប្រសិនបើអ្នកជួបនរណាម្នាក់ដែលពិការ ៖

## សូមកុំ . . .

សម្លឹងមើល ចង្អុល ឬខ្សឹបខ្សៀវគ្នាអំពីពួកគេ ។
ព្រងើយកន្តើយនឹងពួកគេ ។
សើចចំអកដល់ពួកគេ ។
ហៅពួកគេដោយពាក្យអាក្រក់ ។

## សូមធ្វើ . . .

និយាយសួស្ដី ហើយធ្វើល្អ ។
សួរសំណួរក្នុងរបៀបមួយគួរសម ។
ការពារពួកគេ ប្រសិនបើមានអ្នកដទៃធ្វើមិនល្អដាក់ពួកគេ ។
សូមចងចាំថា ពួកគេគឺជាបុត្ររបស់ព្រះ ដូចជាអ្នកផងដែរ !

